Washington State Department of Social & Health Services
Transforming lives

DEVELOPMENTAL DISABILITIES ADMINISTRATION (DDA)

# ព័ត៌មានគម្រោងសង្គ្រោះបន្ទាន់ផ្ទាល់ខ្លួន

# Personal Emergency Plan Information

ប្រើបែបបទនេះបង្កើតគម្រោង ក្នុងករណីមានការសង្គ្រោះបន្ទាន់ ។ បំពេញគម្រោងជាមួយគ្រួសារ មិត្តភក្តិ និងអ្នកផ្តល់ការថែទាំ ដើម្បីកំណត់ពីរបៀបដែលអ្នកនឹងទាក់ទងគ្នាទៅវិញទៅមក កន្លែងដែលអ្នកនឹងជួប និងអ្វីដែលអ្នកនឹងធ្វើក្នុងការសង្គ្រោះបន្ទាន់ ។ រក្សាច្បាប់ចម្លងនៃគម្រោងនេះក្នុងថង់សម្ភារៈសង្គ្រោះបន្ទាន់ ឬកន្លែងសុវត្ថិភាពផ្សេងទៀតដែលអ្នកអាចយកវា ក្នុងករណីមានការសង្គ្រោះបន្ទាន់ ។ កុំបញ្ជូនបែបបទនេះត្រឡប់ទៅអ្នកគ្រប់គ្រងសំណុំរឿងរបស់អ្នក ។

| ព័ត៌មានទាក់ទងផ្ទាល់ខ្លួន | | |
|---|---|---|
| ឈ្មោះរបស់អ្នក | លេខទូរស័ព្ទ | អាសយដ្ឋានអ៊ីមែល |
| អាសយដ្ឋានផ្លូវ | | ផ្លូវបំបែកដែលនៅជិតបំផុត |

| ព័ត៌មានទាក់ទងសង្គ្រោះបន្ទាន់ | | |
|---|---|---|
| ឈ្មោះ លេខទូរស័ព្ទ និងអាសយដ្ឋានអ៊ីមែលនៃបុគ្គល ដើម្បីទាក់ទងពេលសង្គ្រោះបន្ទាន់ ។ | | |
| ឈ្មោះទំនាក់ទំនងក្នុងតំបន់ | ទំនាក់ទំនង | |
| លេខទូរស័ព្ទ | លេខទូរស័ព្ទដៃ | អាសយដ្ឋានអ៊ីមែល |
| ឈ្មោះទំនាក់ទំនងក្នុងតំបន់ | ទំនាក់ទំនង | |
| លេខទូរស័ព្ទ | លេខទូរស័ព្ទដៃ | អាសយដ្ឋានអ៊ីមែល |
| ឈ្មោះទំនាក់ទំនងនៅក្រៅតំបន់ | ទំនាក់ទំនង | |
| លេខទូរស័ព្ទ | លេខទូរស័ព្ទដៃ | អាសយដ្ឋានអ៊ីមែល |

| ក្នុងករណីសង្គ្រោះបន្ទាន់ តើនរណានឹងមកមើលសុខទុក្ខរបស់អ្នក? | | | |
|---|---|---|---|
| ឈ្មោះ | ទំនាក់ទំនង | លេខទូរស័ព្ទ | អាសយដ្ឋានអ៊ីមែល |
| ឈ្មោះ | ទំនាក់ទំនង | លេខទូរស័ព្ទ | អាសយដ្ឋានអ៊ីមែល |

| ទីតាំងជួបពេលសង្គ្រោះបន្ទាន់ | |
|---|---|
| ទីតាំងដែលអ្នកនឹងជួបគ្រួសារ មិត្តភក្តិ និងអ្នកផ្តល់ការថែទាំក្នុងពេលសង្គ្រោះបន្ទាន់ | |
| ទីតាំងជម្លៀសចេញ | លេខទូរស័ព្ទ |
| ទីតាំងជួបជុំនៅជិតខាង | លេខទូរស័ព្ទ |
| ទីតាំងជួបជុំក្នុងតំបន់ | លេខទូរស័ព្ទ |

| ព័ត៌មានទាក់ទងទាក់ទងវេជ្ជសាស្ត្រសំខាន់ | | | | |
|---|---|---|---|---|
| គ្រូពេទ្យសំខាន់ | លេខទូរស័ព្ទ | ឈ្មោះថ្នាំ | កម្រិតថ្នាំត្រូវប្រើ | ចំនួនប្រើ |
| ឱសថការី | លេខទូរស័ព្ទ | | | |
| ឧបករណ៍វេជ្ជសាស្ត្រដែលអ្នកអាចត្រូវការក្នុងការសង្គ្រោះបន្ទាន់ ៖ | | | | |

| តើគួរតែដឹងអ្វីខ្លះអំពីអ្នក ឬផ្ទះរបស់អ្នក បើមានគេមកជួយអ្នកក្នុងពេលសង្គ្រោះបន្ទាន់? |
|---|
| |

## ដំបូន្មានរៀបចំការសង្គ្រោះបន្ទាន់

### ត្រៀមខ្លួន

បុគ្គលដែលបង្កើតគម្រោងសម្រាប់ការសង្គ្រោះបន្ទាន់ បង្កើនឱកាសមានជីវិតរស់របស់ពួកគេទំរាំជំនួយអាចមកដល់ ។

ក្នុងអំឡុងសង្គ្រោះបន្ទាន់ អ្នកអាចត្រូវបានប្រាប់ដោយមន្ត្រីរដ្ឋ និងក្នុងតំបន់ឲ្យនៅក្នុងផ្ទះ ។ មនុស្សគ្រប់រូបគួរតែត្រៀមខ្លួនរួចរាល់ក្នុងការថែទាំខ្លួនឯងនៅផ្ទះយ៉ាងហោចណាស់ឲ្យបានបីថ្ងៃ ។ ផ្ទះរបស់អ្នកអាចជាជម្រកតែមួយគត់របស់អ្នក ទំរាំជំនួយអាចមកដល់ ។ តារាងពិនិត្យនេះអាចជួយអ្នកត្រៀមខ្លួនសម្រាប់ការសង្គ្រោះបន្ទាន់ ។

ស្តាប់ការធ្វើបច្ចុប្បន្នភាពពីមន្ត្រី អំពីថាតើអ្នកគួរតែនៅក្នុងផ្ទះ ឬចាកចេញ ។ វិទ្យុដែលដំណើរការដោយថ្មពិល គឺជាវិធីល្អបំផុតក្នុងការទទួលការធ្វើបច្ចុប្បន្នភាពពីមន្ត្រី ដោយសារអគ្គិសនី និងសេវាកម្មទូរស័ព្ទអាចមិនដំណើរការ ។

កុំស្មានជំនួយនឹងមក ។ ធ្វើគម្រោងសង្គ្រោះបន្ទាន់ផ្ទាល់ខ្លួន ។ បើអ្នកនឹងត្រូវការជំនួយក្នុងអំឡុងពេលសង្គ្រោះបន្ទាន់ រួមទាំងបុគ្គលដែលនឹងជួយអ្នកក្នុងគម្រោងរបស់អ្នក ។ បញ្ជាក់ជាមួយពួកគេយ៉ាងទៀងទាត់ ដើម្បីធានាថាពួកគេនៅទំនេរ ដើម្បីជួយអ្នកក្នុងការសង្គ្រោះបន្ទាន់ ។

ត្រូវប្រាកដថាគម្រោងរបស់អ្នកត្រូវបានធ្វើបច្ចុប្បន្នភាព និងសម្ភារៈសង្គ្រោះបន្ទាន់របស់អ្នកមិនហួសកាលកំណត់ ។

### កម្មវិធីជំនួយ

កម្មវិធីជំនួយពិសេសអាចមានសម្រាប់អ្នកក្នុងព្រឹត្តិការណ៍សង្គ្រោះបន្ទាន់ ។ សាកសួរផ្នែកអគ្គីភ័យ ប៉ូលីស និងការិយាល័យគ្រប់គ្រងការសង្គ្រោះបន្ទាន់ក្នុងតំបន់របស់អ្នក បើពួកគេផ្តល់កម្មវិធីនោះ ។ ចុះឈ្មោះជាមួយក្រុមហ៊ុនអគ្គិសនី និងទឹកក្នុងតំបន់របស់អ្នក បើអ្នកពឹងផ្អែកលើអគ្គិសនីសម្រាប់ឧបករណ៍វេជ្ជសាស្ត្រ ។

### ត្រៀមសម្រាប់ប្រភេទសង្គ្រោះបន្ទាន់ខុសៗគ្នា

ពេលធ្វើគម្រោងរបស់អ្នក ពិចារណាប្រភេទសង្គ្រោះបន្ទាន់ខុសៗគ្នា ដូចជាអគ្គីភ័យ រញ្ជួយដី ខ្យល់ព្យុះ ឬរលកយក្សស៊ូណាមិ ។ ត្រៀមថង់សម្ភារៈសង្គ្រោះបន្ទាន់ ដែលមានសម្ភារៈគ្រប់គ្រាន់ និងគម្រោងសង្គ្រោះបន្ទាន់ដែលមានជំនួយគ្រប់គ្រាន់ ។

### សម្ភារៈសង្គ្រោះបន្ទាន់

ពិចារណារក្សាទុកវត្ថុខាងក្រោមនៅកន្លែងដែលអ្នកងាយស្រួលយកពួកវាក្នុងពេលសង្គ្រោះបន្ទាន់ ៖

- វិទ្យុដែលដំណើរការដោយថ្មពិល និងថ្មពិលបន្ថែម
- វត្ថុអនាម័យផ្ទាល់ខ្លួន
- ទូរស័ព្ទមិនត្រូវការអគ្គិសនី
- ឧបករណ៍ផ្តល់សញ្ញា ដូចជាកញ្ចែ និងកញ្ចក់
- អាហារ ៖ សម្រាប់ 3 ថ្ងៃ សម្រាប់មនុស្សម្នាក់នៃអាហារកញ្ចប់ដែលងាយស្រួលចម្អិន ។
- ចង្ក្រានអាំងសាច់ ឬហ្គាសតូច និងក្រដាសអាលុយមីញ៉ូម
- ឈើគូសមិនជ្រៀបទឹក ទៀន និងឥន្ធនៈសម្រាប់ចម្អិន
- ពិល និងថ្មពិលបន្ថែម
- ពូកក្រាលគេង និងភួយបន្ថែម
- វត្ថុធ្វើឲ្យកក់ក្តៅ
- ឧបករណ៍បើកកំប៉ុង
- ថ្នាំដែលអ្នកប្រើសម្រាប់រយៈពេលពីរសប្តាហ៍
- ចានក្រដាស និងប្រដាប់ប្រើប្រាស់ប្លាស្ទិច
- ច្បាប់ចម្លងនៃក្រដាសសំខាន់ៗ (ព័ត៌មានធានារ៉ាប់រង ប័ណ្ណសម្គាល់ ជាដើម ។)
- ឧបករណ៍ប្រើប្រាស់ច្រើនមុខ
- សម្ភារៈសង្គ្រោះបឋម
- សាច់ប្រាក់ (ប្រាក់រាយ និងក្រដាសប្រាក់តូច)
- អាហារពិសេស
- ទឹក ៖1 ហ្គាឡុងសម្រាប់មនុស្សម្នាក់ ក្នុងមួយថ្ងៃ សម្រាប់រយៈពេលយ៉ាងហោចណាស់ 3 ថ្ងៃ
- អាហារ និងទឹកសម្រាប់សត្វ ឬសត្វចិញ្ចឹម
- សម្លៀកបំពាក់ ស្រោមដៃ និងស្បែកជើងរឹងមាំបន្ថែម
- ប្រដាប់ក្មេងលេង សៀវភៅ ល្បែងតម្រៀប ហ្គេម
- សម្ភារៈវេជ្ជសាស្ត្រ